សហប្រតិបត្តិការអន្តរជាតិ សមាគម និងស្ថាប័នផ្សេង ។ ដើម្បីសហការប្រឆាំងនឹងគ្រឿងញៀន ។

-រៀបចំផែនការប្រឆាំងគ្រឿងញៀនស្របតាមគោលការណ៍អន្តរជាតិ និង តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់បង្ក្រាបគ្រឿងញៀន ។

-ចូលរួមប្រជុំ ស្តីអំពីការបង្ក្រាបគ្រឿងញៀននៅក្នុងប្រទេស និង ក្រៅប្រទេស ។

-រៀបចំកម្មវិធីហ្វឹកហ្វឺនកងកម្លាំងនគរបាលជាតិ អំពីការទប់ស្កាត់ និង បង្ក្រាបគ្រឿងញៀន ។

-អនុវត្តភារកិច្ចផ្សេង ។ ទៀតពាក់ព័ន្ធនឹងគ្រឿងញៀន ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនប្រគល់អោយ ។

**មាត្រា ៣ :** ការរៀបចំជាក់ស្តែងនូវភារកិច្ច និង រចនាសម្ព័ន្ធរបស់មន្ទីរប្រឆាំងគ្រឿងញៀន ត្រូវកំណត់ដោយប្រកាសរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៥

## អនុក្រឹត្យ លេខ ៦៩ អនក្រ.បក

## ស្តីពីការបង្កើតសាលាកសិកម្មកំពង់ចាម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាម ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សំរេច**

**មាត្រា ១ :** បង្កើតសាលាកសិកម្មនៅ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ដែលមានឈ្មោះថា សាលាកសិកម្មកំពង់ចាម (សកកច) ដែលស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២ :** សាលាកសិកម្មកំពង់ចាម មានភារកិច្ចដូចតទៅ ៖

- បណ្តុះបណ្តាល និងសុក្រឹត្យការអ្នកបច្ចេកទេសកំរិតមធ្យម បឋម និង បំពាក់បំប៉នហ្វឹកហ្វឺនវគ្គខ្លី ។ តាមមុខវិជ្ជាឯកទេសកសិកម្មក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ចាត់តាំងអោយមានការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស និង ការងារផលិតកម្មលើវិស័យកសិកម្ម ។
- ស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀនអោយបានសមស្របទៅតាមលក្ខណៈទឹកដី នៃប្រទេសជាតិ ។
- បណ្តុះបណ្តាល និងសុក្រឹត្យការទៅតាមសេចក្តីត្រូវការ ទាំងគុណកោសល្យ និងជំនាញ ។
- កសាងគំរោងផែនការអភិវឌ្ឍន៍សាលាកសិកម្មកំពង់ចាម អោយបានសមស្របទៅតាមការរីកចំរើនរបស់សង្គមកម្ពុជា ។

**មាត្រា ៣ :** សាលាកសិកម្មកំពង់ចាម មានថ្នាក់ស្មើនឹងមន្ទីរជំនាញនៅតាមខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជានិងមាននាយកមួយរូបទទួលខុសត្រូវរួម និងនាយករងជាជំនួយការ ។

**មាត្រា ៤ :** សាលាកសិកម្មនេះ ទទួលបន្ទុកបណ្តុះបណ្តាលជាដំបូងលើមុខជំនាញ ៣ គឺ ៖

១- ក្សេត្រសាស្ត្រ

២–ផលិតកម្ម និង បសុព្យាបាល

៣–ដំណាំកៅស៊ូ

ផ្អែកលើការរីកចំរើន នៃខឿនសេដ្ឋកិច្ចជាតិ និង សមត្ថភាពរបស់សាលាកសិកម្មនេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ អាចបើកបណ្តុះបណ្តាលនូវមុខជំនាញចាំបាច់ផ្សេង ៗ ទៀត ដែលពាក់ព័ន្ធលើវិស័យកសិកម្មក្រៅពីមុខជំនាញដែលរៀបរាប់ខាងលើ ។

**មាត្រា ៥ :** ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់សាលាកសិកម្មកំពង់ចាម ត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ ក្របខ័ណ្ឌមន្ត្រីរាជការរបស់សាលានេះ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអ្នកកំណត់អោយប្រើប្រាស់ ។

**មាត្រា ៦ :** សាលាកសិកម្មកំពង់ចាម ស្ថិតនៅលើដីដែលជាកម្មសិទ្ធិ នៃអតីតសាលាបណ្តុះបណ្តាល វិជ្ជាជីវៈមិត្តភាពកម្ពុជា–ហុងគ្រី ។ ខេត្តកំពង់ចាម ត្រូវសិរ្សលផ្តល់ដីនេះដល់សាលាកសិកម្ម កំពង់ចាម ។

**មាត្រា ៧ :** បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមកពាក់ព័ន្ធ និង សាលាកសិកម្មកំពង់ចាម ហើយផ្ទុយ ពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ស្ថាប័នមានការពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៩ :** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និងត្រា** | **ហត្ថលេខានិងត្រា** |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * * *